Beth Israel Lahey Health
Winchester Hospital

# សេចក្ដីសង្ខេបភាសាសាមញ្ញនៃគោលនយោបាយជំនួយផ្នែកហិរញ្ញវត្ថុ

មន្ទីរពេទ្យ Winchester ជាមន្ទីរពេទ្យសម្រាកព្យាបាលដែលមិនស្វែងរកប្រាក់ចំណេញ ដែលត្រូវបានបង្កើតឡើងដើម្បីបម្រើសេចក្ដីត្រូវការរបស់ប្រជាជនក្នុងរដ្ឋ Massachusetts និងតំបន់ជុំវិញ។ មន្ទីរពេទ្យប្ដេជ្ញាចិត្តក្នុងការផ្ដល់សេវាវេជ្ជសាស្ត្រដល់អ្នកជំងឺ ដោយមិនគិតពីលទ្ធភាពក្នុងការទូទាត់ប្រាក់របស់ពួកគេ។ មន្ទីរពេទ្យ Winchester ទទួលស្គាល់ថា មិនមែនអ្នកជំងឺទាំងអស់សុទ្ធតែមានធនធានហិរញ្ញវត្ថុ ដើម្បីទូទាត់វិក្កយបត្រមន្ទីរពេទ្យនោះទេ។ សេចក្ដីសង្ខេបជាភាសាសាមញ្ញនេះផ្ដល់នូវព័ត៌មានមូលដ្ឋាន អំពីគោលនយោបាយជំនួយផ្នែកហិរញ្ញវត្ថុរបស់យើង។

## គោលនយោបាយជំនួយផ្នែកហិរញ្ញវត្ថុរបស់មន្ទីរពេទ្យ **Winchester**

បុគ្គលិកប្រឹក្សាផ្នែកហិរញ្ញវត្ថុរបស់យើងនឹងជួយបុគ្គលម្នាក់ៗក្នុងការដាក់ពាក្យស្នើសុំកម្មវិធីធានារ៉ាប់រងសុខភាពរបស់រដ្ឋាភិបាលដែលសមស្រប និងបំពេញពាក្យស្នើសុំជំនួយហិរញ្ញវត្ថុដោយឥតគិតថ្លៃ។ កម្មវិធីជំនួយហិរញ្ញវត្ថុផ្ដល់ការសង្គ្រោះបន្ទាន់ និងសេវាកម្មចាំបាច់ផ្នែកវេជ្ជសាស្ត្រផ្សេងទៀតដែលសមស្រប ដោយឥតគិតថ្លៃដល់អ្នកជំងឺដែលមានលក្ខណ: សម្បត្តិគ្រប់គ្រាន់។ មិនថាអ្នកជំងឺគ្មានធានារ៉ាប់រង ឬធានារ៉ាប់រងបានតិចតួចនោះទេ ពួកគេអាចដាក់ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុបាន។ នៅពេលទទួលបានការអនុម័ត អ្នកជំងឺអាចនឹងទទួលបានជំនួយដូចខាងក្រោម ដោយផ្អែកលើសមតុល្យរបស់អ្នកជំងឺលើសេវាកម្មវេជ្ជសាស្ត្រដែលត្រូវរ៉ាប់រង៖

ការព្យាបាលដោយសប្បុរសធម៌

| កម្រិតភាពក្រីក្ររបស់រដ្ឋ | ចំនួននៃជំនួយ |
|---|---|
| នៅកម្រិត ឬក្រោម 400% | 100% |

ការលំបាកក្នុងការទូទាត់ផ្នែកវេជ្ជសាស្ត្រ
ការបញ្ចុះតម្លៃ ១០០% សម្រាប់អ្នកជំងឺដែលវិក្កយបត្រព្យាបាលរបស់គេច្រើនជាង ឬស្មើនឹង ២៥% នៃប្រាក់ចំណូលគ្រួសារសរុបរបស់ពួកគេ។
**សំគាល់៖** មន្ទីរពេទ្យមិនមែនដៃគូធានារ៉ាប់រង សហធានារ៉ាប់រង និងការកាត់កង សុទ្ធតែមិនមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុទេ។ មិនមានករណីណាដែលអ្នកជំងឺដែលទទួលបានជំនួយហិរញ្ញវត្ថុនឹងត្រូវបានគិតថ្លៃច្រើនជាងចំនួនទឹកប្រាក់លើវិក្កយបត្រទូទៅសម្រាប់អ្នកជំងឺប្រើប្រាស់សេវាធានារ៉ាប់រងនោះឡើយ។

## វិធីដើម្បីទទួលបានឯកសារនៃពាក្យស្នើសុំ និងគោលនយោបាយកម្មវិធីជំនួយហិរញ្ញវត្ថុរបស់យើង

អ្នកអាចទទួលបានឯកសារគោលនយោបាយ និងពាក្យស្នើសុំរបស់យើងដោយឥតគិតថ្លៃ តាមមធ្យោបាយខាងក្រោម:

- https://www.winchesterhospital.org/my-visit/insurance-billing--records/financial-assistance
- ទៅកាន់ការិយាល័យពិគ្រោះយោបល់ផ្នែកហិរញ្ញវត្ថុរបស់យើង ដែលមានទីតាំងនៅ៖
  មន្ទីរពេទ្យ និងមជ្ឈមណ្ឌលវេជ្ជសាស្ត្រ Lahey
  សាលធំ
  41 Mall Road
  Burlington MA, 01803
- ស្នើសុំឯកសារឲ្យផ្ញើតាមប្រៃសណីយ៍ ឬជាអេឡិចត្រូនិក ដោយទូរស័ព្ទមកលេខ (៧៨១) ៧៤៤-៨៨១៥ (អ្នកក៏អាចហៅមកលេខនេះ ដើម្បីស្នើសុំជំនួយក្នុងដំណើរការដាក់ពាក្យស្នើសុំផងដែរ។)

## គោលនយោបាយ ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ និងឯកសារសង្ខេបជាភាសាសាមញ្ញអាចរកបាននៅក្នុងភាសាជាច្រើន

គោលនយោបាយ ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ និងឯកសារសង្ខេបជាភាសាសាមញ្ញ មានភាសាដូចខាងក្រោម៖

| | | |
|---|---|---|
| បារាំង | គ្រីអូល (ហៃទី) | អ៊ីតាលី |
| ប៉ទុយហ្គាល់ | ក្រិក | រុស្ស៊ី |
| អាម៉ានី | ហ៊ិនឌី | គូជូរ៉ាទី |
| ផានចាប៊ី | ចិន (សាមញ្ញ) | ចិន (ដើម) |
| អេស្ប៉ាញ | ជប៉ុន | កូរ៉េ |
| ខ្មែរ | វៀតណាម | អារ៉ាប់ |
| អង់គ្លេស | | |

## វិសាលភាពនៃគោលនយោបាយជំនួយផ្នែកហិរញ្ញវត្ថុ

អ្នកជំងឺត្រូវតែដាក់ពាក្យស្នើសុំកម្មវិធីធានារ៉ាប់រងសុខភាពរបស់ រដ្ឋាភិបាលក្នុងរយ:ពេល ៦ ខែនៃការដាក់ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ ដើម្បីមានសិទ្ធិទទួលបានជំនួយពីមន្ទីរពេទ្យ Winchester។ អ្នកជំងឺ ឬ អ្នកធានាអាចដាក់ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុគ្រប់ពេលរហូតដល់ពីររយសែសិប (២៤០) ថ្ងៃ បន្ទាប់ពីទទួលបានវិក្កយបត្រអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យលើកដំបូង។

ប្រគល់ពាក្យស្នើសុំដែលបានបំពេញរួចរបស់អ្នកមក៖
ការិយាល័យប្រឹក្សាយោបល់ផ្នែកហិរញ្ញវត្ថុ
41 Mall Road
Burlington MA, 01803
ប្រសិនបើអនុម័ត ជំនួយផ្នែកហិរញ្ញវត្ថុអាចប្រើប្រាស់បាននៅ៖

- មន្ទីរពេទ្យ Anna Jaques
- មន្ទីរពេទ្យ Addison Gilbert
- មន្ទីរពេទ្យ BayRidge
- មជ្ឈមណ្ឌលវេជ្ជសាស្ត្រ Beth Israel Deaconess
- មន្ទីរពេទ្យ Beth Israel Deaconess Milton
- មន្ទីរពេទ្យ Beth Israel Deaconess Needham
- មន្ទីរពេទ្យ Beth Israel Deaconess Plymouth
- មន្ទីរពេទ្យ Beverly
- មន្ទីរពេទ្យ និងមជ្ឈមណ្ឌលវេជ្ជសាស្ត្រ Lahey
- មជ្ឈមណ្ឌលវេជ្ជសាស្ត្រ Lahey, Peabody
- មន្ទីរពេទ្យ Mount Auburn
- មន្ទីរពេទ្យ New England Baptist
- មន្ទីរពេទ្យ Winchester

**សម្គាល់៖** គ្រូពេទ្យមួយចំនួនមិនត្រូវបានរាប់បញ្ចូលនៅក្នុងគោលនយោបាយជំនួយផ្នែកហិរញ្ញវត្ថុរបស់មន្ទីរពេទ្យ Winchester ទេ។ សូមចូលមើលគេហទំព័ររបស់យើង ឬទំនាក់ទំនងមកកាន់លេខ (៧៨១) ៧៤៤-៨៨១៥។